សនកពតមានសពថាវាកសាង

# ថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើង៖ *តើលោកអ្នកត្រូវដឹងអ្វីខ្លះ*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សេចក្ដីថ្លែងការណ៍នៃព័ត៌មានអំពីថ្នាំវ៉ាក់សាំងជាច្រើនគឺអាចរកបានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ ចូលមើល www.immunize.org/vis

## 1. ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

**ថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើង** អាចការពារ **ជំងឺស្វិតដៃជើង**។

ជំងឺស្វិតដៃជើង (ឬ poliomyelitis) គឺជាជំងឺពិការ និងគំរាមកំហែងដល់អាយុជីវិតដែលបង្កឡើងដោយមេរោគប៉ូលីយ៉ូ ដែលអាចឆ្លងដល់ខួរឆ្អឹងខ្នងរបស់មនុស្សដែលនាំឱ្យខ្វិន។

មនុស្សភាគច្រើនដែលឆ្លងមេរោគជំងឺស្វិតដៃជើង ពុំមានរោគសញ្ញាទេ ហើយមនុស្សជាច្រើននាក់ជាសះស្បើយឡើងវិញ ដោយគ្មានកើតរោគផ្សេងឡើយ។ មនុស្សមួយចំនួនមានអការៈឈឺបំពង់ក ក្ដៅខ្លួន អស់កម្លាំង ចង្អោរ ឈឺក្បាល ឬឈឺពោះ។

មនុស្សមួយក្រុមតូចមានរោគសញ្ញាធ្ងន់ធ្ងរជាង ដែលអាចប៉ះពាល់ដល់ខួរក្បាល និងខួរឆ្អឹងខ្នង៖

- Paresthesia (អារម្មណ៍ហាក់មានម្ជុលចាក់នៅក្នុងជើង)
- ស្រោមខួរក្បាល និងឆ្អឹងខ្នង (ការឆ្លងរោគស្រោមខួរ និង/ឬខួលក្បាល) ឬ
- ខ្វិន (ផ្នែកនៃរាងកាយមិនអាចផ្លាស់ទី) ឬភាពទន់ខ្សោយនៅក្នុងដៃ ជើង ឬអវៈយវៈទាំងពីរ។

ខ្វិនគឺជារោគសញ្ញាធ្ងន់ធ្ងរបំផុតដែលទាក់ទងជាមួយនឹងជំងឺស្វិតដៃជើង ពីព្រោះវាអាចនាំឱ្យមានពិការភាពជាអចិន្ត្រៃយ៍ និងអាចស្លាប់បាន។

ភាពប្រសើរឡើងនៃការខ្វិនអវៈយវៈអាចកើតមានឡើង ប៉ុន្តែចំពោះមនុស្សមួយចំនួន ការឈឺចាប់សាច់ដុំ និងភាពទន់ខ្សោយអាចវិវត្តពី 15 ទៅ 40 ឆ្នាំក្រោយ។ អការៈនេះត្រូវបានគេហៅថា "រោគសញ្ញាក្រោយជំងឺស្វិតដៃជើង"។

ជំងឺស្វិតដៃជើងត្រូវបានលុបបំបាត់ពីសហរដ្ឋអាមេរិក ប៉ុន្តែវានៅតែកើតមាននៅតំបន់ផ្សេងទៀតនៃពិភពលោក។ មធ្យោបាយដ៏ល្អបំផុតដើម្បីការពារខ្លួនអ្នក និងធ្វើឱ្យសហរដ្ឋអាមេរិកគ្មានជំងឺស្វិតដៃជើង គឺត្រូវរក្សាភាពស៊ាំខ្ពស់ (ការការពារ) នៅក្នុងចំនួនប្រជាជន និងប្រឆាំងនឹងជំងឺស្វិតដៃជើងតាមរយៈការចាក់វ៉ាក់សាំង។

## 2. ថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើង

**កុមារ** ជាធម្មតាគួរចាក់វ៉ាក់សាំងជំងឺស្វិតដៃជើង ចំនួន 4 ដងនៅអាយុ 2 ខែ 4 ខែ 6-18 ខែ និង 4-6 ឆ្នាំ។

**មនុស្សពេញវ័យ**ភាគច្រើនមិនត្រូវការថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើងទេ ព្រោះពួកគេបានទទួលថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើងរួចហើយ ពេលនៅជាកុមារ។ មនុស្សពេញវ័យមួយចំនួន មានហានិភ័យខ្ពស់ ហើយគួរពិចារណាទទួលថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើងនេះ ក្នុងនោះរួមបញ្ចូល៖

- មនុស្សដែលធ្វើដំណើរទៅកាន់តំបន់ណាមួយនៅលើពិភពលោក
- បុគ្គលិកនៃមន្ទីរពិសោធន៍ ដែលប្រហែលធ្វើពិសោធន៍លើមេរោគជំងឺស្វិតដៃជើង
- បុគ្គលិកថែទាំសុខភាព ដែលព្យាបាលអ្នកជំងឺ ដែលអាចមានមេរោគជំងឺស្វិតដៃជើង
- អ្នកដែលមិនបានទទួលថ្នាំវ៉ាក់សាំងដែលកូនរបស់ពួកគេនឹងទទួលថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើង (ឧទាហរណ៍ កូនចិញ្ចឹមអន្តរជាតិ ឬជនភៀសខ្លួន)

វ៉ាក់សាំងការពារជំងឺស្វិតដៃជើង អាចត្រូវបានផ្តល់ជាវ៉ាក់សាំងដាច់តែឯង ឬជាផ្នែកនៃវ៉ាក់សាំងរួមបញ្ចូលគ្នា (ប្រភេទវ៉ាក់សាំងដែលរួមបញ្ចូលគ្នានូវវ៉ាក់សាំងច្រើនជាងមួយរួមគ្នាទៅក្នុងការចាក់វ៉ាក់សាំងម្តង)។

ថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើងអាចចាក់ឲ្យក្នុងពេលដំណាលគ្នានឹងថ្នាំវ៉ាក់សាំងដទៃទៀត។

## 3. និយាយជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក

ប្រាប់អ្នកផ្តល់វ៉ាក់សាំងរបស់អ្នក ប្រសិនបើបុគ្គលនោះទទួលវ៉ាក់សាំង៖

- មាន **ប្រតិកម្មអាលែហ្ស៊ី បន្ទាប់ពីការចាក់ថ្នាំបង្ការជំងឺស្វិតដៃជើងពីមុន** ឬមាន **អាឡែស៊ីធ្ងន់ធ្ងរ និងគំរាមកំហែងដល់អាយុជីវិត**

ក្នុងករណីខ្លះ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចសម្រេចចិត្តពន្យាពេលការចាក់វ៉ាក់សាំងការពារជំងឺស្វិតដៃជើង រហូតដល់ការណាត់ជួបនាពេលខាងមុខ។

អ្នកដែលមានជំងឺស្រាល ដូចជាជំងឺផ្តាសាយ អាចទទួលថ្នាំបង្ការនេះបាន។ អ្នកដែលមានជំងឺធ្ងន់ល្មម ឬធ្ងន់ធ្ងរ គួររង់ចាំ រហូតដល់ពួកគេជាសះស្បើយសិន មុនពេលទទួលថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើង។

U.S. Department of Health and Human Services
Centers for Disease Control and Prevention

មិនត្រូវបានគេដឹងច្រើនអំពីហានិភ័យនៃវ៉ាក់សាំងនេះចំពោះអ្នកមានផ្ទៃពោះ ឬបំបៅដោះកូននោះទេ។ ទោះជាយ៉ាងណាក៏ដោយ វ៉ាក់សាំងការពារជំងឺស្វិតដៃជើងអាចត្រូវបានផ្តល់ឱ្យ ប្រសិនបើ អ្នកមានផ្ទៃពោះមានហានិភ័យខ្ពស់ក្នុងការឆ្លងមេរោគ ហើយត្រូវការ ការការពារជាបន្ទាន់។

អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នកអាចផ្តល់ព័ត៌មានបន្ថែមដល់លោកអ្នកបាន។

## 4. ហានិភ័យនៃប្រតិកម្មថ្នាំវ៉ាក់សាំង

- កន្លែងឈឺ ដែលមានអការៈក្រហម ហើម ឬឈឺ ចាប់ នៅកន្លែងចាក់ថ្នាំអាចកើតឡើង បន្ទាប់ពី ចាក់វ៉ាក់សាំងជំងឺស្វិតដៃជើង។

ពេលខ្លះ មនុស្សសន្លប់ បន្ទាប់ពី ដំណើរការវេជ្ជសាស្ត្ររួមទាំងការចាក់ថ្នាំវ៉ាក់សាំង។ សូមប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក ប្រសិនបើលោកអ្នកវិលមុខ ឬចក្ខុញ្ញាណផ្លាស់ប្តូរ ឬឮសំឡេងហឹងក្នុងត្រចៀក។

ដូចថ្នាំផ្សេងទៀតដែរ ថ្នាំវ៉ាក់សាំងកម្រនឹងបង្កប្រតិកម្មអាលែហ្ស៊ី ធ្ងន់ធ្ងរ ឬរបួសធ្ងន់ធ្ងរផ្សេងទៀត ឬការបាត់បង់ជីវិត។

## 5. ចុះបើមានបញ្ហាធ្ងន់ធ្ងរឬ?

ប្រតិកម្មអាលែហ្ស៊ី អាចកើតឡើងបន្ទាប់ពី អ្នកទទួលថ្នាំបង្ការ ចាកចេញពីគ្លីនិក។ ប្រសិនបើ អ្នកឃើញសញ្ញានៃប្រតិកម្មធ្ងន់ធ្ងរ (កន្ទួលកហម ហើមមុខ និងបំពង់កពិបាកដកដង្ហើម បេះដូងលោតញាប់ វិលមុខ ឬខ្សោយ) សូមទូរស័ព្ទទៅ **9-1-1** ហើយនាំអ្នកជំងឺ ទៅមន្ទីរពេទ្យដែលនៅជិតបំផុត។

សម្រាប់សញ្ញាផ្សេងទៀតដែលទាក់ទងនឹងអ្នក សូមទូរស័ព្ទទៅអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។

ប្រតិកម្មទៅប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំងគួរតែត្រូវបានរាយការណ៍ ទៅ Vaccine Adverse Event Reporting System (VAERS)។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកជាធម្មតានឹងដាក់របាយការណ៍ នេះ ឬអ្នកអាចធ្វើវាដោយខ្លួនឯងបាន។ សូមចូលទៅគេហទំព័រប្រព័ន្ធរាយការណ៍ ផលអាក្រក់នៃថ្នាំវ៉ាក់សាំង (VAERS) [www.vaers.hhs.gov](www.vaers.hhs.gov) ឬទូរស័ព្ទទៅលេខ **1-800-822-7967**។ *ប្រព័ន្ធរាយការណ៍ ផលអាក្រក់នៃថ្នាំ(VAERS) សម្រាប់តែការ រាយការណ៍ ប៉ុណ្ណោះ។ បុគ្គលិករបស់ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំ (VAERS) មិនផ្តល់ដំបូន្មានអំពី វេជ្ជសាស្ត្រទេ។*

Khmer translation provided by Immunize.org

## 6. កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង

National Vaccine Injury Compensation Program (កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (VICP)) គឺជាកម្មវិធី របស់រដ្ឋសហព័ន្ធ ដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។ ការទាមទារទាក់ទងនឹងរបួស ឬការស្លាប់ដោយសារការ ទទួលថ្នាំ បង្ការ មានពេលវេលាកំណត់សម្រាប់ការដាក់ឯកសារ ដែលអាចមានរយៈពេល ខ្លីត្រឹមពីរឆ្នាំ។ សូមចូលទៅគេហទំព័រកម្មវិធីជាតិ បង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (VICP) [www.hrsa.gov/vaccinecompensation](www.hrsa.gov/vaccinecompensation) ឬទូរស័ព្ទទៅលេខ **1-800-338-2382** ដើម្បីសិក្សាអំពី កម្មវិធី និងការដាក់ពាក្យទាមទារ។

## 7. តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- សូមចូលទៅ Food and Drug Administration (គេហទំព័ររដ្ឋបាលអាហារនិងឱសថ (FDA)) ដើម្បីទទួលបានកញ្ចប់សេវាកម្មថ្នាំបង្ការ និងព័ត៌មានបន្ថែម [www.fda.gov/vaccines-blood-biologics/vaccines](www.fda.gov/vaccines-blood-biologics/vaccines)។
- Centers for Disease Control and Prevention (សូមទាក់ទងមជ្ឈមណ្ឌលទប់ស្កាត់ និងបង្ការជំងឺ (CDC))៖
  - សូមទូរស័ព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលមើលគេហទំព័ររបស់ CDC នៅ [www.cdc.gov/vaccines](www.cdc.gov/vaccines)។

[illegible] Michigan Care Improvement Registry ។ [illegible]

DCH-0470CA
AUTH: P. H. S., Act 42, Sect. 2126.